# ចិត្តមនុស្សក្នុងលោក

## បទបន្ទោលកាក

វេហាស៍ធំឆ្ងាយ សត្វហើរប្រញាយជាខ្សែ
ស្រែកយំហូរហែ រាល់ខែរាល់ឆ្នាំមិនថ្វី ។
យន្តហោះផ្លោតផ្លោះ សន្ទឹកលាន់អស់លោកិយ
មេឃាធ្វើហី មិនស្ដីមិនខឹងមនុស្សា ។
ឯដួងចិត្តមនុស្ស ចំលែកប្លែកខុសវេហាស៍
គ្មានរូបឡើយណា ក្រលាបានសព្វបែបយ៉ាង ។
លោភក្រោធឥច្ឆា ប្រាថ្នាជំទើតក្អេងក្អាង
មានះមិនស្វាង សំអាងទ្រព្យយសសិទ្ធី ។
មុខមាត់កិត្តិយស អំណាចកេរ្តិ៍ឈ្មោះលាភី
បៀតបៀនយាយី ជាន់ឈ្លីល្មើសសិទ្ធិសេរី ។
ខ្លះឃើញអ្នកទាប ទុកភាពមិនស្មើដុំដី
ឃើញអ្នកក្រក្រី ធ្វើហីមិនខ្វីចងមិត្ត ។
វក់តែអញឯង ជំទែងសំដែងឥទ្ធិឫទ្ធី
កោតតែមិនគិត ខំតែប្រឌិតទោសផង ។
ជាតិមនុស្សដូចគ្នា ទោះខុសទោះជាម្ដាលម្ដង
រាប់ដូចប្អូនបង ក្ដីហ្មងបាត់លែងមានមោះ ។
ឱចិត្តមនុស្សា គួរណាតែឈប់ទុយិស
ទោះលើកខ្លួនខ្ពស់ ក៏មិនផុតហួសម្រឹត្យូវ ។
ចុងក្រោយដូចគ្នា ទោះខំពើងពារពេញផ្លូវ
ពេលដាច់ខ្យល់ទៅ នឹងត្រូវអស់អ្វីក្អេងក្អាង ។

Ca. ០៧ ឧសភា ២០០៦